# การใช้และการธำรงภาษาเขมรถิ่นในบทเพลงพื้นบ้านสุรินทร์

บัญญัติ สาลี
มหาวิทยาลัยมหาสารคาม ประเทศไทย

**บทคัดย่อ**

บทความนี้มีวัตถุประสงค์เพื่อศึกษาลักษณะการใช้ภาษาเขมรถิ่นในบทเพลงพื้นบ้านของชาวเขมรสุรินทร์ ศึกษาทั้งลักษณะการใช้ภาษาและการใช้สำนวนในบทเพลงพื้นบ้าน ผลการศึกษาพบว่า บทเพลงพื้นบ้านเขมรถิ่นสุรินทร์แบ่งเป็น 2 ประเภท คือ บทเพลงที่ใช้ในวิถีชีวิตและความเชื่อ ได้แก่ เพลงกล่อมเด็ก เพลงการละเล่นมะม็วด การแซนโฎนตาม และการรำตรุษ 2. บทเพลงที่ใช้ในการแสดง ได้แก่ บทเพลงกันตรึมและเจรียง การใช้ภาษาของกลุ่มชาติพันธุ์เขมรนี้นิยมใช้ภาษาเขมรถิ่นปนกับภาษาไทย นอกจากนี้ยังมีการใช้สำนวนที่เป็นแสดงถึงอัตลักษณ์ภาษาเขมรถิ่นสุรินทร์ ซึ่งเป็นภาษามรดกที่ปรากฏในบทเพลงพื้นบ้านอันประกอบด้วยสำเนียง คำ  และความหมายของคำ ภาษาทั้งหมดนั้นมีลักษณะที่แตกต่างจากภาษาเขมรมาตรฐานหรือภาษาเขมรในปัจจุบัน

**คำสำคัญ** ภาษาเขมรถิ่นสุรินทร์ บทเพลงพื้นบ้าน

# ការប្រើប្រាស់និងការទ្រទ្រង់ក្រាមភាសាខ្មែរនៅក្នុងបទចម្រៀងប្រជាប្រិយ ក្នុងខេត្តសុរិន្ទ្រ

Banyat Salee

Mahasarakham University, Thailand

## មូលន័យសង្ខេប

អត្ថបទនេះមានវត្ថុបំណងសិក្សាលក្ខណៈការប្រើប្រាស់គ្រាមភាសាខ្មែរនៅក្នុងបទចម្រៀងប្រជាប្រិយរបស់អ្នកស្រុកសុរិន្ទ្រ ទាំងការប្រើភាសានិងការរៀបចំពាក្យពេចន៍នៅក្នុងបងទចម្រៀង ។ ការសិក្សារកឃើញថា ចម្រៀងប្រជាប្រិយនៅខេត្តសុរិន្ទ្រមានពីប្រភេទ គឺ ១. ចម្រៀងដែលប្រគំក្នុងការកំសាន្ត និងក្នុងពិធីកម្មជំនឿ ដូចជាការបំពេរកូន ចូលមេមត់ សែនដូនតា និងត្រុត ២. ចម្រៀងដែលប្រើក្នុងការសម្ដែង ដូចជារបាំកន្ទ្រឹម និងចម្រៀងឯទៀត ។ ការប្រើភាសារបស់ជាតិពិន្ទុខ្មែរ និយមប្រើពាក្យក្នុងខ្មែរអ្នកស្រុកច្រើន និងផ្សំជាមួយភាសាថៃផងដែរ ។ ក្រៅពីនេះនៅមានពាក្យពេចន៍ខ្មែរសុរិន្ទ្រដែលជាមរតកក្នុងចម្រៀងប្រជាប្រិយ ដែលមានសំនៀង ពាក្យ និងន័យរបស់ពាក្យ ។ ពាក្យទាំងនោះអាចមានលក្ខណៈប្លែកអំពីភាសាខ្មែរកណ្ដាល ឬខ្មែរបច្ចុប្បន្ន ។

ពាក្យគន្លឹះ៖ ភាសាខ្មែរសុរិន្ទ្រ ចម្រៀងប្រជាប្រិយ

## សេចក្ដីផ្ដើម

ភាសាខ្មែរសុរិន្ទ្រជាគ្រាមភាសាមួយដែលមានការនិយាយនៅក្នុងខេត្តសុរិន្ទ្រតាំងពីបុរាណកាលមកដល់បច្ចុប្បន្នកាល ។ ភ័ស្តុតាងគឺមានសិលាចារឹកដែលចាស់ជាងគេបំផុត គឺ សិលាចារឹកនៃព្រះបាទមហេន្ទ្រវរ្ម័នដែលគេរកឃើញហើយយកទៅរក្សាទុកនៅសាលសសរស្ដម្ភទីក្រុងឬសាលឡាក់មឿង សរសេរជាភាសាសំស្ក្រឹត និងមានសិលាចារឹកប្រសាទតាមាន់ដែលគេរក្សាទុកនៅសារមន្ទីជាតិសុរិន្ទ្រសរសេរជាភាសាខ្មែរ ។ ភ័ស្តុតាងទាំងនេះបង្ហាញឱ្យឃើញថា ទីកន្លែងនានានៃខេត្តសុរិន្ទ្រមានក្រុមជាតិពន្ធរស់នៅមកយូរជាងគេបំផុតគឺ ជាតិពន្ធខ្មែរ ។ ទោះបីក្រុមជាតិពន្ធកួយបានមានអំណាចនិងបានកាន់កាប់តំបន់នោះក្នុងសម័យពញាសុរិន្ទ្រភក្ដីស្រីណរង្គចាងវាង ឆ្នាំ ១៧១៧ ក្ដី ក៏ជាតិពន្ធខ្មែរនៅតែរស់នៅទីនោះរហូតដោយមិនបានភៀសខ្លួនទៅនៅតំបន់ឯណាផ្សេងពីនោះទេ ។ ខ្មែរនៅតែរស់លាយឡំនៅជាមួយជាតិពន្ធកួយជាដរាបរៀងមក ។ កូនចៅរបស់ចៅហ្វាយខេត្ត ស៊ុន បានរៀបការជាមួយនិងរាជបុត្រខ្មែរមានព្រះនាមថា នាងតាម បុត្រីនៃស្ដេចក្រុងបន្ទាយពេជ្រ ។ ភាសាខ្មែរគឺជាភាសាដែលអ្នកស្រុកសុរិន្ទ្រគ្រប់គ្នាបានប្រើប្រាស់នៅក្នុងស្ទើរទូទាំងខេត្តសុរិន្ទ្រ ។

ចម្រៀងប្រជាប្រិយខ្មែរនៅខេត្តសុរិន្ទ្រជាស្នាដៃរបស់ជាតិពន្ធខ្មែរ ដែលបានច្នៃប្រឌិតរៀបចំជាបទចម្រៀងដែលបង្ហាញអត្តសញ្ញាណរបស់ខ្លួន និងបានបង្ហាត់បង្រៀនបន្តពីកូនចៅជំនាន់មួយទៅជំនាន់មួយ និងបានបន្សល់រហូតដល់បច្ចុប្បន្ន ។ បទចម្រៀងនេះច្រៀងជាភាសាខ្មែរសុរិន្ទ្រឬហៅថាគ្រាមភាសាខ្មែរសុរិន្ទ្រ ។ ពាក្យពេចន៍ដែលក្នុងបទចម្រៀងទាំងនេះជាពាក្យដែលត្រូវនឹងពាក្យក្នុងភាសាខ្មែរផងនិងពាក្យខ្មែរដែលប្រើតែក្នុងទឹកដីសុរិន្ទ្រ ពោលគឺមានភាពស្រដៀងគ្នានិងភាពខុសគ្នាទៅនឹងភាសាខ្មែរស្ដង់ដារ ។ បទចម្រៀងបានបង្ហាញអំពីការអភិរក្សពាក្យនិងការទ្រទ្រង់គ្រាមភាសាខ្មែរផងដែរ ។

## លក្ខណៈទូទៅនៃភាសាខ្មែរសុរិន្ទ្រ

ភាសាខ្មែរសុរិន្ទ្រគឺជាគ្រាមភាសាដែលប្រើសម្រាប់ប្រាស្រ័យទាក់ទងគ្នាទាំងក្នុងភាសាសរសេរ និង ភាសានិយាយ កាលពីអតីតកាល ។ ភស្តុតាងទាំងនេះបានបង្ហាញតាមរយៈស្នាដៃបូរាណវិទ្យាមួយចំនួនដូចជា សាស្ត្រាស្លឹករឹត និងឯកសារសំណេរ ក្នុងទម្រង់មិនទាន់មានការឯកភាពគ្នានៅឡើយទេ ។ ឧទាហរណ៍ដូចជា ៖



Transliteration : nih saṭra mahacāti nagara kān khae 13 hon̊

Transcription : nih satraa mhaciat nakharakan khasɛɛ bɔjtanɔp hoŋ

រូបទី ១. ស្លឹករឹត

នៅពេលដែលនាំរូបសំណេខាងលើមកប្រៀបធៀបជាមួយនឹងសំណេរភាសាខ្មែរបច្ចុប្បន្ន យើងសង្កេតឃើញ ថាមានលក្ខណៈត្រូវគ្នាច្រើន ។ តែមានពាក្យខ្លះប្រើប្រាស់ការសរសេរសម្រាប់អានប៉ុណ្ណោះ ។ ព្រោះថាពេលនោះមិនទាន់មានការប្រើប្រាស់វចនានុក្រមសម្រាប់សរសេរនៅឡើយទេ ។

នាបច្ចុប្បន្ននេះភាសាខ្មែរសុរិន្ទ្រប្រើក្នុងកម្រិតត្រឹមភាសានិយាយប៉ុណ្ណោះ ។ ក្នុងភាសានេះមានព្យញ្ជនៈ ២២ និងស្រៈ ៣៤ (Premsrirat Suwilai and other, 2533) ។ យើងអាចនិយាយបានថា ព្យញ្ជនៈដើមព្យាង្គមានចំនួនត្រូវគ្នាព្យញ្ជនៈនៅក្នុងភាសាខ្មែរស្តង់ដារ ក្នុងនោះព្យញ្ជនៈ រ នៅប្រើជាព្យញ្ជនៈចុងព្យាង្គក្នុងពាក្យមួយចំនួន ។

ร [-r] ខ្មែរសុរិន្ទ្រ /–r/ ខ្មែរស្តង់ដារ /- ɸ /

ពាក្យ ការ [kār] ខ្មែសុរិន្ទ្របញ្ចេញសំឡេងថា /kaar/ ផ្ទុយទៅវិញ ខ្មែរស្តង់ដារបញ្ចេញសំឡេងពាក្យនេះថា /kaa/

ស្រៈក្នុងគ្រាមភាសាខ្មែរសុរិន្ទ្រក៏មានលក្ខណៈខុសប្លែកគ្នាទៅនឹងស្រៈក្នុងភាសាខ្មែរ ព្រោះខាងខ្មែរសុរិន្ទ្រមានចំនួនស្រៈច្រើនជាង ដូចជា ៖

| | Front | Middle | Back |
|---|---|---|---|
| High | i<br>ii | ɯ<br>ɯɯ | u<br>uu |
| Mid-high | ɩ<br>ɩɩ | ɤ ɤ<br>ɤ | ʊ<br>ʊʊ |
| Middle | e<br>ee | ə<br>əə | o<br>oo |
| Mid-low | ɛ<br>ɛɛ | ʌ<br>ʌʌ | ɔ<br>ɔɔ |
| Low | | a<br>aa | ɑ<br>ɑɑ |

ការប្រៀបធៀបលក្ខណៈដូចគ្នានិងការបញ្ចេញសំឡេងស្រៈភាសាខ្មែរសុរិន្ទ្រជាមួយនឹងភាសាខ្មែរកណ្តាល ដូចជា ៖

| | ភាសាខ្មែរសុរិន្ទ្រ | ភាសាខ្មែរស្តង់ដារ |
|---|---|---|
| ប្អូន [buan] | /ʊʊ/ | /ua/ |
| | /bʊʊn/ | /buan/ |

ក្លី [klɔɔ] /ʌʌ/ /ɔɔ/

/klʌʌ/ /klɔɔ/

រៀន [rian] ɯ ia

/rɯn/ /rian/

**លក្ខណៈចម្រៀងខ្មែរសុរិន្ទ្រ**

ចម្រៀងខ្មែរសុរិន្ទ្រប្រើប្រាស់សំនៀងគ្រាមភាសាអ្នកសុរិន្ទ្រ និងមានការបែងចែកជាពីរប្រភេទគឺ

១) **ចម្រៀងប្រើក្នុងពិធីកម្មនានា** ក្រុមជាតិពន្ធុប្រើច្រៀងរាំក្នុងពិធី ជំនឿសាសនា ប្រពៃណី និងការកំសាន្ត ។ កម្រងចម្រៀងទាំងនោះមានដូចជា បទបំពេកូន ភ្លេងបញ្ជាន់អារក្ស ភ្លេងសែនដូនតា និង របាំត្រុតជាដើម ។

បទបំពេកូន

ស្លាលីង

ប្អូននឹកស្រណោះស្លាលីង ខ្លួនប្អូននៅក្មេង

បងបញ្ឆោតស្លាលន់ បងបញ្ឆោតប្អូនហើយ

បងទៅយកប្រពន្ធ បងបញ្ឆោតស្លាលន់

ឱ្យហានខ្មាស់គេ

(ម្ចាស់អត្ថបទសូមរក្សា ពាក្យពេចន៍ដែលប្រើក្នុងបទចម្រៀង និងចម្រៀងសុរិន្ទ្រឯទៀតក្នុងអត្ថបទនេះ តាមសំនៀងខ្មែរសុរិន្ទ្រ )

២). **ចម្រៀងដែលប្រើក្នុងការសម្តែង** គឺសំដៅទៅលើបទចម្រៀងដែលក្រុមជាតិពន្ធុបានបង្កើតឡើងដើម្បីឲ្យមានការសប្បាយរីករាយក្នុងការសម្តែងនៅក្នុងទីកន្លែងសាធារណៈ ទីប្រជុំជន ។ មានដូចជា កន្ទ្រឹម[1]ព្រមទាំងមានចម្រៀងដូចជា

បទកន្ទ្រឹម

អុំទូក

បងអុំទូកទៅ ចង្វាលូតព្រាត

បងស្រែក ប្តាំញាតិ មីខ្មៅ បងផង

ប្តាំទៅកល់ តាំងក្បួត មូលព្រាត់ ចំណាង

[1] នៅក្នុងសំនៀងខ្មែរសុរិន្ទ្រ ពាក្យ កន្ទ្រឹម បញ្ចេញសំឡេងជា កាន់ទ្រឹម ។ ក្នុងអត្ថបទនេះ យើងសម្រេចប្រើពាក្យ កន្ទ្រឹម ។

| | |
|---|---|
| មីខ្មៅបងផង | ក្រែងវាស៊ីក្បែ |
| បងអុំទូកទៅ | ទូកធំក្ដត់ |
| បងអុំតាមបទ | តាមស្រីឆ្នាំរូង |
| បងត្បេសមុទ្រ | ត្បាតកន្ទង |
| តាមស្រី ឆ្នាំរូង | ឆ្នាំមួយ ផងគ្នា |
| បងគិតសប់ថ្ងៃ | គិតស្រីមាសមី |
| គិតប្អូនភ្វា | ប្រសើរ ថ្លៃថ្លា |
| បងអុំទូកទៅ | ទូកធំកាំប៉ាង |
| បងអុំរ៉ាបខាង | ចាំចាប់ ក្រមុំចិន |
| បងណាង់ចាប់ ក្រមុំខ្មែរ | ស៊ីស្លា ប៉ាង់ហេន |
| បងចាំចាប់ ក្រមុំចិន | បានស៊ីផង លក់ផង។ |
| | និពន្ធដោយ ប៊ុន ឱសុម |
| | ច្រៀងដោយ ណាំភឹង មឿងសុរិន្ទ |

## ការប្រើប្រាស់ភាសាខ្មែរក្នុងបទចម្រៀងនិងល្បែងប្រជាប្រិយខ្មែរសុរិន្ទ

### ១. ការប្រើពាក្យមិនសុភាព

ការប្រើប្រាស់ភាសាក្នុងជីវភាពប្រចាំថ្ងៃ ពាក្យភាគច្រើនអ្នកស្រុកអាចយល់គ្នាជាទូទៅ ពោលគឺមិនបាច់មានការបកប្រែឬអធិប្បាយណាមួយនៅក្នុងចំណោមអ្នកស្រុកសុរិន្ទ ។ ទោះយ៉ាងណាក្ដី មានពាក្យមួយចំនួនត្រូវបានប្រើសម្រាប់បង្ហាញន័យមិនពិរោះ ។ ក្នុងនោះ ពាក្យថា ស៊ី ប្រើបានក្នុងការនិយាយទាំងមនុស្សទាំងសត្វ ដូចបទចម្រៀងខាងក្រោមនេះ

បទបំពេកូន

អាណាយដេកទៅ

| | |
|---|---|
| អើ អើ អើ | ដេកទៅឱ្យលក់ |
| ស្រមុកឱ្យខ្លាំង | ឱ្យមានកម្លាំង |
| ក្រោកឡើង**ស៊ីបាយ** | **ស៊ីបាយ**រួចហើយ |

.......

បទបំពេកូន

កណ្ឌូបទិងតង់ (កណ្តូបទិងតង់)

| | |
|---|---|
| កណ្ឌូបទិងតង់ | **ស៊ីស្លឹក**ឫស្សី |
| ក្រមុំម៉ាមួយ | កន្លោះបី |
| .......... | |

(ណាំភឹង មឿងសុរិន្ទ)

ពាក្យថា នោម ដូចបទចម្រៀងខាងក្រោមនេះ

បទ បានប្អូម (បាយផ្អូម)

| | |
|---|---|
| អូ កន្ត្រែត ៗ អើយ | កន្ត្រែត ៗ បាយប្អូម |
| ប្រដាច់ក្បិនចូលនោម | ក្រោមវត្តលោកតា |
| ........... | |

## ២. ការប្រើពាក្យផ្គួន

ការប្រើពាក្យផ្គួនជាលក្ខណៈពិសេសនៅក្នុងបទចម្រៀងបំពេរកូនរបស់ខ្មែរសុរិន្ទ្រ ។ បទចម្រៀងប្រភេទនេះមានប្រើពាក្យផ្គួនក្នុងស្ទើរគ្រប់បទ ។

បទបំពេកូន ផ្គរលាន់

| | |
|---|---|
| ផ្គរលាន់**ក្លួងក្លួង** | ញ៉ុមដាក់ដៃលើ**ទ្រូង** |
| **ទ្រូង**ញ៉ុមហ្ន៎កាំព្រា | **ទ្រូង**គេមានគ្នីគ្នា |
| **ទ្រូង**អូនកាំព្រា | ម្តាយអើយ |
| ដេករងាម្នាក់ឯង | |

## ៣. ការប្រើពាក្យដែលបង្ហាញការប្រៀបធៀប

បទកន្ទ្រឹម

កន្ទួយគូទវៀច

| | |
|---|---|
| គេថាអ្នក**ក្ទួយគូថវៀច** | ដើរមកពីខាងលិច |
| ដីខ្សាច់ជិតខ្នង | មកដល់ផ្ទះម៉ែជីរំពង់ |
| ..................... | |

បទកន្រ្ទឹម

អាយ៉ៃអាយ៉ង

**កញ្ញាញ់**ចេកអើយ លូតទុំ**កញ្ញាញ់**

កូនផ្សាចូលដេក ម៉ែក្មេកលូចមើល

..................

( ណាំភឹង មឿងសុរិន្ទ )

## ៤. ការប្រើពាក្យថៃលាយជាមួយពាក្យខ្មែរសុរិន្ទ្រ

បទកន្រ្ទឹម

ផាលនិងអន្ទុល ( ម្ទុល )

អេ៎... ផាលចាស់មិនយក ទៅរកតែផាល់ថ្មីៗ

...............................

អេ៎..អន្ទុលស្មានថៃ ស្រីមិន**តងកាន**

អន្ទុលស្មានថៃ ស្រីមិន**តងកាន**

នាងមិនចង់បាន **តងកានកេះកះ**

បងអើយ**តងកានកេះកះ**

( ស្មានថៃ-ភិមផា )

ពាក្យថៃថា តងការ មានន័យថា ត្រូវការ

កេះកះ មានន័យថា គ្មានសណ្តាប់ធ្នាប់

បទ ម៉េះសុំតាង

ម៉េះសុំតាង ម៉េះសុំតាង ម៉េះសុំតាង

....................

( ឌុង ឌយ )

ពាក្យថា តាង មានន័យថា លុយ មកពីពាក្យថា ស្តាង្គ ។

## ការអនុរក្សភាសាខ្មែរសុរិន្ទ្រតាមរយៈបទចម្រៀងសុរិន្ទ្រ

ការអនុរក្សពាក្យខ្មែរសុរិន្ទ្រជាប្រការសំខាន់មួយ ដោយហេតុថា ភាសានេះកំពុងឈានទៅរកការបាត់បង់ ។ បច្ចុប្បន្នភាសាខ្មែរសុរិន្ទ្រចាប់ផ្តើមបាត់បង់បន្តិចម្តង ៗ ។ ក្មេងជំនាន់ក្រោយមិននិយម

ប្រើភាសាខ្មែរ បែរជាចូលចិត្តនិយាយគ្នាជាភាសាថៃ ។ អ្នកដែលប្រើភាសាខ្មែរជាអ្នកដែលរស់នៅតាមស្រុកស្រែចំការ ប៉ុន្តែអ្នកទាំងនោះក៏មិនបានប្រើភាសាខ្មែរទាំងអស់ដែរ ។ នេះចាត់ទុកថាជាវិបត្តិមួយសម្រាប់ភាសាខ្មែរក្នុងប្រទេសថៃ ។ មានក្រុមការងារ ក៏ដូចជាស្ថាប័នមួយចំនួនព្យាយាមអនុរក្សរក្សាភាសាខ្មែរសុរិន្ទ្រឲ្យបានគង់វង់ តាមរយៈការបំផុសឲ្យមានការបើកបង្រៀនភាសាខ្មែរសុរិន្ទ្រនៅតាមបណ្តាសាលារៀននានា ។ ក្នុងនោះ សាលារៀនភូមិពោធិកងបានចាប់ផ្តើមដំណើរការបង្រៀន ដោយមានការសហការជាមួយសាកលវិទ្យាល័យមហិឌុល ។ ប៉ុន្តែកម្មវិធីសិក្សាមិនបានប្រើប្រាស់អក្សរខ្មែរក្នុងការសរសេរទេ គឺគេប្រើអក្សរថៃក្នុងការសរសេរពាក្យខ្មែរសុរិន្ទ្រទាំងនោះ ។ ប្រការនេះអាចមកពីនៅក្នុងខេត្តមានការខកខានប្រើអក្សរខ្មែរក្នុងរយៈពេលយូរយារមកហើយ ។




រូបទី ២ សិស្សសាលារៀនភូមិពោធិ៍កងកំពុងរៀនភាសាខ្មែរសុរិន្ទ្រដោយប្រើអក្សរថៃ

ស្របពេលជាមួយគ្នានេះ រាជបណ្ឌិត្យសភានៃព្រះរាជាណាចក្រថៃបានចងក្រងឯកសារណែនាំអំពីការប្រើអក្សរថៃក្នុងការសរសេរពាក្យខ្មែរសុរិន្ទ្រផងដែរ ។




រូបទី ៣ ឯកសារណែនាំអំពីការសរសេរភាសាខ្មែរសុរិន្ទ្រដោយអក្សរថៃ ច្បាប់បោះពុម្ព ដោយរាជបណ្ឌិត្យសភាថៃ

ទន្ទឹមនឹងនោះ ការអនុរក្សភាសាខ្មែរសុរិន្ទ្រដែលលេចធ្លោរជាងគេ គឺនៅក្នុងខេត្តសុរិន្ទ្រមានអ្នកនិពន្ធនិងសិល្បករច្រើន ។ ក្រៅពីនេះនៅមានហាងមួយចំនួនបានជួយឧបត្ថម្ភក្នុងការតែងនិពន្ធនិងការច្រៀងចម្រៀងកន្ទ្រឹមផងដែរ ដូចជា ផៃរោចន៍សោនដ៍ ។




រូបទី ៤ ផៃរោចន៍សោនដ៍ អ្នកឧបត្ថម្ភសិល្បករកន្ទ្រឹម

ក្រៅពីនេះ នៅមានការបង្កើតបទចម្រៀងខារ៉ាអូខេចម្រៀងខ្មែរសុរិន្ទ្រផងដែរ ។



រូបទី ៥ កន្រ្ទឹមខារ៉ាអូខេដោយអក្សរថៃ

នៅក្នុងខារ៉ាអូខេទាំងនោះ ក៏មានការប្រើតួអក្សរខ្មែរស្តង់ដារសម្រាប់យកទៅផ្សព្វផ្សាយនៅប្រទេសកម្ពុជាផងដែរ ដោយហេតុថា ខ្មែរភាគច្រើននៃប្រទេសកម្ពុជាមានការនិយមចម្រៀងប្រភេទនេះដែរ ។ ចំណុចនេះបង្ហាញឲ្យឃើញថា ការអនុរក្សភាសាខ្មែរសុរិន្ទ្របានធ្វើឡើងផងដែរតាមរយៈសិល្បៈកន្រ្ទឹម ។



រូបទី ៦ កន្រ្ទឹមខារ៉ាអូខេដោយតួអក្សរខ្មែរ

## សេចក្តីសន្និដ្ឋាន

ការប្រើនិងការអភិរក្សភាសាខ្មែរសុរិន្ទ្រនៅក្នុងបទចម្រៀងប្រជាប្រិយខ្មែរសុរិន្ទ្របានឆ្លុះបញ្ចាំងអំពីអត្តសញ្ញាណនៃខ្មែរសុរិន្ទ្រ ។ ទោះជាភាសាខ្មែរសុរិន្ទ្រមានការផ្លាស់ប្តូរមួយចំនួនកើតឡើងនៅក្នុងការប្រើប្រាស់ពាក្យ ការបញ្ចេញសំឡេង ដែលលក្ខណៈទាំងនោះមិនដូចគ្នានឹងភាសាខ្មែរស្តង់ដារ ហើយមានពាក្យភាសាថៃចូលមកលាយឡំក្តី ក៏នេះចាត់ទុកថា ការប្រើភាសាខ្មែរសុរិន្ទ្រនៅមានការអនុរក្សលក្ខណៈដើម ។ ពាក្យថ្មីដែលប្រើក្នុងបទចម្រៀង លើកលែងពាក្យដែលប្រើក្នុងជីវភាពប្រចាំថ្ងៃ មិនមែនជាពាក្យដែលខ្មែរសុរិន្ទ្របានបង្កើតថ្មីទេ ។ ពាក្យទាំងនោះមានមួយចំនួនជាពាក្យថៃដែលត្រូវយកមកប្រើដើម្បីបង្គ្រប់ពាក្យដែលភាសាខ្មែរសុរិន្ទ្រមិនមាន ។ ចម្រៀងប្រជាប្រិយខ្មែរសុរិន្ទ្រមានតួនាទីសំខាន់ក្នុងការអភិរក្សភាសាខ្មែរសុរិន្ទ្រ ព្រោះអាចចូលដល់ប្រិយមិត្តអ្នកស្តាប់គ្រប់ស្រទាប់ ។ មនុស្សថៃបានស្គាល់ពាក្យ កន្ទ្រឹម ឬ កាន់ទ្រឹម និងជាប់ពាក្យទំនៀមថា កន្ទ្រឹមនៅទីណា ភាសាខ្មែរនៅទីនោះ ។

## ឯកសារយោង


ឃោស៊ិត ឪស៊ុំ (2544) ការវិវត្តនៃកន្ទ្រឹមភូមិដុងម៉ាន់ ឃុំកគោ ស្រុកមឿង ខេត្តសុរិន្ទ្រ. មហាសារខាម : សាកលវិទ្យាល័យមហាសារខាម

បញ្ញត្តិ សាលី (2554) បទបំពេកូនខ្មែរក្នុងភូមិឦសានខាងត្បូង. មហាសារខាម : សាកលវិទ្យាល័យមហាសារខាម

ពណ៌រាយ ខាំសោភា (2540) កន្ទ្រឹមនិងចម្រៀងប្រជាប្រិយខេត្តសុរិន្ទ្រ. សុរិន្ទ្រ : សាកលវិទ្យាល័យរាជផាត់សុរិន្ទ្រ

ភូមចិត្ត រឿងដេជ (2550) ការលេងកន្ទ្រឹម ភ្លេងប្រជាប្រិយខ្មែរក្នុងខេត្តបុរីរម្យនិងសុរិន្ទ្រ. សុរិន្ទ្រ : សាកលវិទ្យាល័យរាជផាត់សុរិន្ទ្រ